# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# កិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ាន-ចិន លើកទី៧
# ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា

១. យើង រដ្ឋមន្ត្រីសុខាភិបាលប្រទេសសមាជិកអាស៊ានតំណាងឱ្យប្រទេសប្រុយណេដារូសាលឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណៈរដ្ឋហ្វីលីពីន សាធារណរដ្ឋសាំងហ្គាពួរ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម និងរដ្ឋមន្ត្រីសុខាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតចិន បានដំណើរការកិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ាន-ចិន លើកទី៧ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ នៅក្រុងសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា។

២. យើងគាំទ្រទាំងស្រុង ចំពោះការដាក់បញ្ចូលនវានុវត្តន៍សម្រាប់ការលើកកម្ពស់គុណភាពសេវាសុខាភិបាល ជាអាទិភាពថ្មីមួយ នៅក្រោមកិច្ចសហប្រតិបត្តិកាសុខាភិបាលអាស៊ាន-ចិន សម្រាប់ឆ្នាំ២០២០-២០២១ ដោយបន្ថែមលើផ្នែកជាអាទិភាពនៃកិច្ចសហប្រតិបត្តិការដែលមានស្រាប់ ក្នុងឆ្នាំ ២០១៩-២០២០ ដូចជាការបង្ការ និងការគ្រប់គ្រងជំងឺមិនឆ្លង លើកកម្ពស់សុខភាពល្អ និងរក្សាភាពសកម្មក្នុងវ័យចំណាស់ ដោះស្រាយជំងឺឆ្លង ដោយផ្តោតលើជំងឺរបេង ជំងឺគ្រុនចាញ់ ជំងឺអេដស៍ និងជំងឺដង្កូវព្រូនស៊ីស្តូសូមីញ៉ា និងកិច្ចសហការរួមគ្នាប្រយុទ្ធជំងឺឆ្លង**កាត់តាម**ព្រំដែន និងពង្រឹងគុណភាពវេជ្ជសាស្ត្របុរាណ។

៣. យើងប្តេជ្ញាពង្រឹងនវានុវត្តន៍សម្រាប់ការលើកកម្ពស់គុណភាពសេវាសុខាភិបាល ដោយប្រើប្រាស់ព័ត៌មាន និងលទ្ធផលសុខភាពដើម្បី ដោះស្រាយបញ្ហាប្រឈម ក្នុងការលើកកម្ពស់គុណភាពសេវាសុខាភិបាល តាមរយៈលើកស្ទួយនវានុវត្តន៍ក្នុងវិស័យសុខាភិបាល អន្តរាគមន៍លើគុណភាព និងធានាបរិស្ថានគាំទ្រ ។ ការប្តេជ្ញាចិត្តនេះ នឹងត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីការងារពាក់ព័ន្ធ នៃកិច្ចសហប្រតិបត្តិការវិស័យសុខាភិបាលអាស៊ាន ហួសពីឆ្នាំ២០២០ ។

៤. យើងប្តេជ្ញាបន្តការពិភាក្សាគ្នា ស្តីអំពី គុណតម្លៃ និង ផលប៉ះពាល់នៃ នវានុវត្តន៍ សម្រាប់ការលើកកម្ពស់គុណភាពសេវាសុខាភិបាលដែលជាប់ពាក់ព័ន្ធជាមួយនឹងដំណើរនៃការច្របាច់បញ្ចូលគ្នានៃ (១)សុវត្ថិភាព (២)ប្រសិទ្ធភាព (៣)ផ្តោតលើអ្នកជំងឺ (៤)ពេលវេលាពិតប្រាកដ (៥)ប្រសិទ្ធពល (៦)សមធម៌ និង(៧)សមាហរណកម្ម។ ដូច្នេះ យើងស្វាគមន៍ចំពោះការចែករំលែកបទពិសោធន៍ និងការអនុវត្តល្អៗ នៅក្នុងតំបន់ ដែលឆ្ពោះទៅគាំទ្រដល់ការផ្តល់សេវាសុខភាពមានគុណភាព សម្រាប់គំនិតផ្តួចផ្តើមផ្នែកសុខភាពជាអាទិភាព ដូចជាការគ្របដណ្តប់សុខភាពជាសកល (UHC) និងកម្មវិធីជាតិជាអាទិភាព ។

៥. យើងបញ្ជាក់អះអាងជាថ្មីម្តងទៀត អំពីការគាំទ្ររបស់យើង ចំពោះការអនុវត្តការគ្របដណ្តប់សុខភាពជាសកល ដើម្បីធានាការទទួលសេវាសុខភាពមានគុណភាព និងប្រសិទ្ធភាព ដោយគ្មានហានិភ័យនៃបន្ទុកហិរញ្ញវត្ថុ ដោយពិចារណាអនុសាសន៍របស់អង្គការសុខភាពពិភពលោក ស្តីពីសេវាសុខភាពដែលចាត់ទុកប្រជាជនជាស្នូល និងការលើកកម្ពស់គុណភាព។

៦. យើងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រឹងគុណភាពវេជ្ជសាស្ត្របុរាណ តាមរយៈការប្រតិបត្តិនូវសកម្មភាពនៃគម្រោងដែលស្ថិតក្រោមកម្មវិធីការងាររបស់ក្រុមការងារសុខភាពអាស៊ានទី៣ និងការអភិវឌ្ឍន៍និងការចែករំលែកគោលការណ៍ណែនាំសម្រាប់ការអនុវត្តន៍វេជ្ជសាស្ត្របុរាណ ។

៧. យើងកត់សំគាល់ពីការរួមចំណែករបស់ដៃគូអភិវឌ្ឍន៍និងដៃគូសន្ទនា ដូច្នេះយើងបន្តប្តេជ្ញាចិត្តសហការយ៉ាងជិតស្និទ្ធជាមួយដៃគូទាំងនោះ ដោយប្រកាន់ភ្ជាប់នូវ «វិធាននិងនិតិវិធីស្តីពីការចូលរួមរបស់អង្គភាពនានា ក្នុងវិស័យសុខាភិបាលអាស៊ាន» ។

៨. យើងសម្លឹងឆ្ពោះទៅរកការផ្លាស់ប្តូរទស្សនៈវិស័យរួមគ្នា និងកិច្ចសហប្រតិបត្តិការបន្ថែមទៀត ក្នុងការអភិវឌ្ឍន៍វិស័យសុខាភិបាល នៅឯកិច្ចប្រជុំលើកក្រោយ ដែលនឹងប្រព្រឹត្តទៅនៅសាធារណរដ្ឋឥណ្ឌូនេស៊ី នៅឆ្នាំ ២០២១ ។

********

FINAL

**JOINT STATEMENT**
**7TH ASEAN CHINA HEALTH MINISTERS MEETING**
**30 AUGUST 2019, SIEM REAP, THE KINGDOM OF CAMBODIA**

1. WE, the Ministers of Health of ASEAN Member States (AMS), representing Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Viet Nam and the Minister of Health of the People's Republic of China convened the 7th ASEAN-China Health Ministers Meeting (ACHMM) on 30 August 2019 in Siem Reap, the Kingdom of Cambodia.

2. We fully support the inclusion of Innovations for Enhancing Quality of Health Services as a new priority area under the ASEAN-China health cooperation for 2020-2021, adding on the existing priority areas of collaboration for 2019-2020 such as prevention and control of non-communicable diseases; promoting healthy and active ageing; addressing communicable diseases with specific focus on tuberculosis, malaria, HIV and AIDS, and schistosomiasis, and cross border-communicable diseases joint collaboration; and, strengthening the quality of traditional and complementary medicine.

3. We commit to strengthen Innovations for Enhancing Quality of Health Services that utilise information and health outcomes to address challenges in enhancing quality of health services through the promotion of health innovations, quality interventions and ensuring an enabling environment for it. This commitment will be included in the relevant work programme of the ASEAN Health Sector Cooperation beyond 2020.

4. We further commit to continue discussion on the value and implications of the Innovations for Enhancing Quality of Health Services that involves the convergence of (1) Safety; (2) Effectiveness; (3) Patient-Focused; (4) Real-time; (5) Efficiency; (6) Equity; and (7) Integration. We thus welcome the sharing of experiences and best practices in the region towards supporting the implementation of health quality services to priority health initiatives such as Universal Health Coverage (UHC) and National Health Priority Programme.

5. We reiterate our support to the implementation of UHC to ensure access to quality and cost-effective health services without risk of financial hardship, taking into consideration the WHO recommendation on people-centered health services and quality improvement.

6. We continue our efforts to strengthen quality of Traditional and Complementary Medicine (T&CM) through the operationalization of project activities under the

Work Programme of the ASEAN Health Cluster 3 and the development and sharing of T&CM practice guidelines.

7. We note the contribution by, and further commit to collaborate closely with Dialogue and Development Partners in adherence to the *Rules of Procedure on the Engagement of Entities with the ASEAN Health Sector*.

8. We look forward to further exchanges of perspectives and collaboration in health development at our next Meeting in the Republic of Indonesia in 2021.

********